**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ៥៦៤៨ ព.ណ....ស.ច

ថ្ងៃចន្ទ ៩រោច ខែមិគសិរ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨

## សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូន អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ជាផលិតករ អ្នកនាំចេញទាំងអស់ ឲ្យបានជ្រាបថាៈ យោងតាមបទប្បញ្ញត្តិរបស់សហភាពអឺរ៉ុប ដែលបានធ្វើវិសោធនកម្មចុងក្រោយ ដោយបញ្ញត្តិ លេខ(EU) 2017/989 ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧ និងដោយផ្អែកតាមប្រកាស អន្តរក្រសួងលេខ ១៦២៧ សហវ-ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ស្តីពីការកែសម្រួលនីតិវិធីក្នុងការបំពេញបែបបទនាំចេញទំនិញទៅក្រៅប្រទេស ក្នុងគោលបំណងសម្រួលពាណិជ្ជកម្ម និងកាត់បន្ថយបន្ទុកចំណាយរបស់អ្នកនាំចេញ ក្រសួងពាណិជ្ជកម្មសូមអំពាវនាវដល់ផលិតករ ឬអ្នកនាំចេញទាំងអស់ដែលមានបំណងនាំចេញទំនិញគ្រប់ប្រភេទពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់សហភាពអឺរ៉ុប (EU) ស្ថិតក្រោមគម្រោង "ការអនុគ្រោះពន្ធលើគ្រប់មុខទំនិញទាំងអស់ លើកលែងគ្រឿងសព្វាវុធ (EBA)" រួមទាំងប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP) របស់ប្រទេសណ័រវេស, ប្រទេសស្វីស និងប្រទេសទួរគី សូមអញ្ជើញមកដាក់ពាក្យសុំចុះឈ្មោះក្នុងប្រព័ន្ធចុះបញ្ជីអ្នកនាំចេញ (Registered Exporter System - REX) របស់សហភាពអឺរ៉ុប នៅនាយកដ្ឋាននាំចេញ-នាំចូល នៃក្រសួងពាណិជ្ជកម្ម ដើម្បីមាននីតិសម្បទាក្នុងការប្រកាសប្រភពដើម (Statement on Origin) ជំនួសឱ្យការប្រើប្រាស់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់អេ ចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១៩ តទៅ ។

-ពាក្យស្នើសុំដូចមានតាមគម្រូភ្ជាប់ក្នុងសេចក្តីជូនដំណឹងនេះ ឬ អាចទាញយកពីគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម (www.moc.gov.kh)។

-ដើម្បីទទួលបានព័ត៌មានលម្អិត សូមទំនាក់ទំនងៈ

១-ឯកឧត្តម ហូ ស៊ីវយ៉ុង ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម និងជាប្រធាននាយកដ្ឋាននាំចេញ-នាំចូល

ទូរស័ព្ទលេខៈ០១២ ៨៣៨ ៩០៩, សារអេឡិចត្រូនិកៈ hosivyong@yahoo.com,

២-លោក ស៊ី បាទិត្យ ប្រធានការិយាល័យនៃនាយកដ្ឋាននាំចេញ-នាំចូល

ទូរស័ព្ទ ៖ ០១២ ៩៤៨ ៤៨៤ សារអេឡិចត្រូនិកៈ sy.batith@moc.gov.kh, batithsy@yahoo.com

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ជាផលិតករ អ្នកនាំចេញទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តឲ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៩ តទៅ ។

**សូមអរគុណ.**

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងពាណិជ្ជកម្ម